# ពិធីការបើកឡើងវិញសម្រាប់ក្រុមគាំទ្រសុខភាពផ្លូវចិត្ត និងវិបត្តិនៃការប្រើប្រាស់សារធាតុញៀន

បច្ចុប្បន្នភាពថ្មីៗ៖

7/8/20៖ បានផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងការកែលម្អប្រព័ន្ធខ្យល់ចេញចូល

7/18/20៖ បានផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងរបាំងមុខ និងការពិនិត្យរោគសញ្ញារបស់បុគ្គលិក និងអ្នកចូលរួម។ (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)

នាយកដ្ឋានសុខភាពសាធារណ:របស់ខោនធី Los Angeles កំពុងអនុវត្តវិធីសាស្ត្រតាមដំណាក់កាល ដែលបានគាំទ្រដោយវិទ្យាសាស្ត្រ និងជំនាញការសុខភាពសាធារណៈ ដើម្បីអនុញ្ញាតឲ្យអាជីវកម្មលក់រាយបើកទ្វារឡើងវិញដោយសុវត្ថិភាព។ ពិធីការបើកឡើងវិញខាងក្រោម គឺជាក់លាក់សម្រាប់ទីកន្លែងនិងសកម្មភាពដែលមានហានិភ័យ (risk) ទាបដែលត្រូវបានអនុញ្ញាតឲ្យបើកឡើងវិញដោយសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលក្នុងខោនធីដែលបានចេញកាលពីថ្ងៃទី 13 ខែឧសភាឆ្នាំ 2020។ បន្ថែមលើល័ក្ខខ័ណ្ឌដែលបានដាក់ទៅលើទីកន្លែងនិងសកម្មភាពជាក់លាក់ទាំងនេះដោយមន្ត្រីសុខាភិបាលសាធារណៈរដ្ឋ ទីកន្លែងនិងសកម្មភាពទាំងនេះ ក៏ត្រូវតែអនុវត្តតាមល័ក្ខខ័ណ្ឌដែលបានចែងនៅក្នុងបញ្ជីត្រួតពិនិត្យសម្រាប់ក្រុមគាំទ្រសុខភាពផ្លូវចិត្ត និងវិបត្តិនៃការប្រើប្រាស់សារធាតុញៀន (Checklist for Substance Use Disorder and Mental Health Support Groups) ដែលភ្ជាប់ជូនខាងក្រោមនេះផងដែរ។

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមានព័ត៌មាន និងធនធានបន្ថែម ដូច្នេះសូមប្រាកដថាពិនិត្យមើលគេហទំព័រ LA County http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំសម្រាប់បច្ចុប្បន្នភាពផ្សេងៗទៅលើឯកសារនេះ។

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់លើជំហានដែលបានរៀបរៀងដើម្បីធានាបាននូវការចាប់ផ្តើមឡើងវិញប្រកបដោយសុវត្ថិភាពនៃក្រុមគាំទ្រសុខភាពផ្លូវចិត្ត វិបត្តិនៃការប្រើប្រាស់សារធាតុញៀន និងក្រុមគាំទ្រព្យាបាលផ្សេងៗទៀតនៅក្នុងកម្មវិធីសុខភាពផ្លូវចិត្ត និងព្យាបាលការប្រើប្រាស់សារធាតុញៀនទាំងមានការស្នាក់នៅ និងមិនមានការស្នាក់នៅ ទីកន្លែងរស់នៅរួមគ្នា ទីជម្រកជនក្មេងផ្លូវសម្បែង និងទីកន្លែងស្រដៀងគ្នា ក៏ដូចជាក្រុមជួយខ្លួនឯងដាច់ពីគេដែលអាចធ្វើឡើងនៅតាមទីកន្លែងជាច្រើន។

ក្រុមគាំទ្រព្យាបាលទាំងនេះ ត្រូវបានតម្រូវឲ្យអនុវត្តតាមការណែនាំសុខភាពសាធារណៈដែលសមស្របទៅតាមទីកន្លែងនិងសកម្មភាពទាំងនោះ ដោយទាក់ទងនឹងសុវត្ថិភាពបុគ្គលិក ការប្រើប្រាស់ការរក្សាគំលាតពិត និងវិធានការណ៍គ្រប់គ្រងការឆ្លងជំងឺ។ ការអនុវត្តដែលមានរាយខាងក្រោម ត្រូវតែអនុវត្តបន្ថែមទៅលើវិធានការណ៍ទាំងនោះ។

**ទីកន្លែងទាំងអស់ដែលចូលរួមក្នុងសកម្មភាពដែលត្រូវបានគ្របដណ្តប់ដោយការណែនាំនេះ ត្រូវតែដាក់ចុះនូវវិធានការណ៍ដែលអាចអនុវត្តបានទាំងអស់ ដែលមានរាយនៅខាងក្រោម និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុនៃវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្ត គឺមិនអាចអនុវត្តបានសម្រាប់ទីកន្លែង។**

**ឈ្មោះក្រុម/ទីកន្លែង៖** ______________________

**អាសយដ្ឋានទីកន្លែង៖** ______________________

**ចំនួនមនុស្សអតិបរមាតាមច្បាប់អគ្គីភ័យ៖** ______________________

**ប្រហាក់ប្រហែលនៃទំហំទីកន្លែងគិតសរុបជាហ្វីតការ៉េ ៖** ______________________

## A. គោលការណ៍ និងការអនុវត្តដើម្បីការពារសុខភាពអ្នកចូលរួម (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ☐ អ្នកចូលរួមទាំងអស់ត្រូវបានប្រាប់ថាមិនឲ្យចូលរួមក្នុងក្រុម បើសិនជាឈឺ ឬបើសិនជាពួកគេបានប៉ះពាល់ជាមួយបុគ្គលដែលមានជំងឺ COVID-19 និងត្រូវអនុវត្តតាមការណែនាំរបស់នាយកដ្ឋានសុខភាពសាធារណៈទាក់ទងនឹងការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក ឬការនៅដាច់ពីគេ ទៅតាមការគួរ។ អ្នកចូលរួមមិនត្រូវបានពិន័យឡើយ បើសិនជាចាំបាច់ត្រូវខកខានការប្រជុំមួយឬច្រើនដងដោយសារជំងឺ ឬការប៉ះពាល់នឹងជំងឺ។
- ☐ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោង ឬពិធីការដើម្បីឲ្យករណីទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យមានការនៅដាច់ពីគេដោយខ្លួនឯងភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀតឬក៏អត់ ដែលអាចតម្រូវឲ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។
- ☐ ការត្រួតពិនិត្យបុគ្គលិក ត្រូវបានធ្វើឡើងមុនពេលបុគ្គលិកអាចនឹងចូលមកកាន់កន្លែងធ្វើការ។ ការត្រួតពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងអការគ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលិកបានប៉ះពាល់ជាមួយបុគ្គលដែលត្រូវបានគេដឹងថាបានឆ្លងជំងឺ COVID-19 ក្នុងរយៈពេល 14 ថ្ងៃចុងក្រោយឬក៏អត់។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានពីចម្ងាយ ឬដោយផ្ទាល់នៅពេលបុគ្គលិកមកដល់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងនៅកន្លែងធ្វើការផងដែរ បើសិនជាអាចធ្វើបាន។
- ☐ ការត្រួតពិនិត្យរោគសញ្ញាត្រូវបានធ្វើឡើងមុនពេលភ្ញៀវឬអ្នកចូលរួមអាចនឹងចូលក្នុងទីកន្លែង។ ការត្រួតពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងអការគ្រុនក្តៅឬគ្រុនរងា។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងដូចជាការចុះឈ្មោះចូលតាមអនឡាញ ឬតាមរយៈស្លាកសញ្ញាដែលបានបិទនៅច្រកចូលទីកន្លែងដោយបញ្ជាក់ថាភ្ញៀវដែលមានរោគសញ្ញាទាំងនេះមិនគួរចូលក្នុងទីកន្លែងឡើយ។
- ☐ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃទទួលបានរបាំងមុខសមស្របដែលគ្របច្រមុះ និងមាត់ដោយឥតគិតថ្លៃ។ បុគ្គលិកត្រូវពាក់របាំងមុខនេះគ្រប់ពេលវេលាក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ ឬទំនងជាប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់របាំងមុខ គួរពាក់សន្ទះបាំងមុខដែលមានក្រណាត់រុំនៅគែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ ដរាបណាស្ថានភាពសុខភាពរបស់ពួកគេអនុញ្ញាតឲ្យធ្វើដូច្នេះ។ ក្រណាត់រុំដែលមានទម្រង់រឹតតឹងខាងក្រោមចង្កាគឺជាការល្អ។ មិនគួរប្រើម៉ាស់ដែលមានវ៉ាល់មួយផ្លូវឡើយ។ បុគ្គលិកមិនចាំបាច់ពាក់ក្រណាត់បាំងមុខពេលនៅម្នាក់ឯងនៅក្នុងការិយាល័យឯកជន ឬបន្ទប់តូចដែលមានរបាំងរឹងការពារខ្ពស់ជាងកម្ពស់បុគ្គលិកនៅពេលឈរនោះទេ។
- ☐ បុគ្គលិកត្រូវបានណែនាំឲ្យបោកគក់ ឬផ្លាស់ប្តូររបាំងមុខរបស់ខ្លួនជារៀងរាល់ថ្ងៃ។
- ☐ នៅក្នុងករណីដែលរកឃើញថាមានករណីចំនួន 3 ឬច្រើនជាងនេះនៅកន្លែងធ្វើការក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកគួររាយការណ៍ពីចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងការងារ នាយកដ្ឋានសុខភាពសាធារណៈនឹងចាប់ផ្តើមការឆ្លើយតបនឹងការឆ្លងជាចង្កោមដែលរួមមានការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ការគាំទ្របច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់តាមតំបន់។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈនឹងត្រូវបានចាត់តាំងសម្រាប់ធ្វើការស៊ើបអង្កេតលើចង្កោមនេះ ដើម្បីជួយដឹកនាំការឆ្លើយតបនៅទីកន្លែង។
- ☐ ច្បាប់ចម្លងនៃពិធីការដែលបានបំពេញរួចនេះត្រូវបានចែកចាយទៅអ្នកចូលរួមនីមួយៗ។
- ☐ ពិធីការនេះ និងឯកសារទាក់ទងនឹងជំងឺ COVID-19 ផ្សេងៗទៀតដែលបានផ្តល់ជាការបកប្រែនៅលើគេហទំព័រមេរោគកូរ៉ូណារបស់ DPH ក្នុងខោនធី ត្រូវបានផ្តល់ឲ្យអ្នកចូលរួមជាភាសារបស់ពួកគេផ្ទាល់ នៅពេលដែលមាន។
- ☐ ស្រេចចិត្ត—ពិពណ៌នាអំពីវិធានការណ៍ផ្សេងទៀត៖

______________________________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតពិត

- ☐ ចំនួនអ្នកចូលរួមសរុបនៅក្នុងក្រុម ដោយរាប់បញ្ចូលទាំងអ្នកចូលរួម និងអ្នកសម្របសម្រួល/អ្នកដឹកនាំក្រុម

មិនអាចលើសពី 10 នាក់ឡើយ។

- ☐ ទៅតាមកម្រិតដែលអាចធ្វើបាន ក្រុមត្រូវបានកំណត់កាលវិភាគនៅពេលវេលាដែលនឹងមិនបណ្តាលឲ្យមានមនុស្សច្រើនកកកុញ ស្របពេលដែលអ្នកចូលរួមមកដល់ច្រកចូល និងច្រកចេញរបស់ទីកន្លែង។
- ☐ កៅអី សាឡុង និងកន្លែងអង្គុយផ្សេងទៀតនៅក្នុងកន្លែងប្រជុំក្រុម ត្រូវបានរៀបចំដើម្បីអនុញ្ញាតឲ្យមានគំលាតយ៉ាងតិច 6 ហ្វីតរវាងអ្នកចូលរួមពីរនាក់។
- ☐ ទៅតាមកម្រិតដែលអាចធ្វើបាន ច្រកចូលកន្លែងប្រជុំត្រូវបានដាក់កម្រិតត្រឹមអ្នកចូលរួម និងអ្នកសម្របសម្រួល/អ្នកដឹកនាំក្រុម។
- ☐ អ្នកចូលរួមក្រុមទាំងអស់ត្រូវតែគោរពតាមការណែនាំរបស់ទីកន្លែងទាក់ទងនឹងការកំណត់ចំនួនមនុស្សនៅក្នុងបន្ទប់ទឹក និងនៅក្នុងទីកន្លែងទូទៅផ្សេងៗ ដោយរាប់បញ្ចូលទាំងទីកន្លែងជក់បារីជិតបន្ទប់ឬកន្លែងប្រជុំ។

## C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

- ☐ ភ្ញៀវដែលមកដល់ទីកន្លែងត្រូវបានរំលឹកឲ្យពាក់របាំងមុខនៅគ្រប់ពេលវេលាខណៈពេលនៅក្នុងទីកន្លែង ឬនៅលើទីធ្លានៃទីកន្លែង។ មានតែបុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់របាំងមុខដោយអ្នកផ្តល់សេវាវេជ្ជសាស្រ្តប៉ុណ្ណោះទើបត្រូវបានលើកលែងពីការពាក់នេះ។ ដើម្បីគាំទ្រសុវត្ថិភាពបុគ្គលិករបស់អ្នក និងភ្ញៀវផ្សេងទៀត គួរផ្តល់របាំងមុខឲ្យភ្ញៀវដែលមកដល់ដោយគ្មានវា។
- ☐ អ្នកចូលរួមក្រុមទាំងអស់ចុះឈ្មោះចូលដោយប្រើប៊ិចរបស់ខ្លួន ឬប្រើប៊ិចដែលត្រូវបានធ្វើអនាម័យរវាងអ្នកប្រើ ឬតាមបែបអេឡិចត្រូនិកដោយប្រើឧបករណ៍ផ្ទាល់ខ្លួន ឬឧបករណ៍ដែលត្រូវបានធ្វើអនាម័យរវាងអ្នកប្រើ។
- ☐ អាហារ ឬភេសជ្ជៈមិនត្រូវបានបម្រើនៅក្នុងការប្រជុំឡើយ ហើយមិនអនុញ្ញាតឲ្យចែករំលែកអាហារ/ភេសជ្ជៈ/បារី/។ល។ ឡើយ
- ☐ ទឹកអនាម័យលាងដៃ ក្រដាសជូតមាត់ និងធុងសម្រាមគឺមានសម្រាប់សាធារណជននៅ ឬជិតច្រកចូល និងច្រកចេញអគារ។
- ☐ ប្រព័ន្ធ HVAC ស្ថិតក្នុងសភាពដំណើរការល្អ នៅតាមកម្រិតអតិបរមាដែលអាចធ្វើបាន ខ្យល់ចេញចូលត្រូវបានបង្កើនឡើង។
  - ☐ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័ត ធ្វើឲ្យប្រសើរឡើងនូវតម្រងខ្យល់របស់អគារឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់ចេញចូលនៅគ្រប់ទីកន្លែងធ្វើការទាំងអស់។
- ☐ ស្រេចចិត្ត – ពិពណ៌នាពីវិធានការណ៍ផ្សេងៗទៀតដើម្បីលើកកម្ពស់ការគ្រប់គ្រងការឆ្លងជំងឺ៖

______________________________________________________________________

**វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែកដែលអ្នកសម្របសម្រួល/អ្នកដឹកនាំក្រុមគួរភ្ជាប់ជាមួយឯកសារនេះ។**

អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖

ឈ្មោះទំនាក់ទំនងក្រុម៖ ______________________ លេខទូរសព្ទ៖ ______________________

កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖ ______________________

ច្បាប់ដើម - មិនមានបកប្រែទេ